

# វិធីបណ្តុះកូនល្ហុង

## ១-ការជ្រើសរើសពូជ:

- ❋ យើងត្រូវជ្រើសរើសដើមល្ហុងធំល្អ ស្លឹកខៀវចាស់ មិនមានរោគហើយយកផ្លែដែលធំវែង មានសំបុរ ពណ៌លឿង មួយឆ្អុត។
- ❋ ពុះផ្លែល្ហុងជាបណ្តោយចំពាក់កណ្តាលហើយ ឆ្កឹះយកគ្រាប់ល្ហុងចេញអោយអស់។
- ❋ រើសយកតែគ្រាប់ណាធំៗ ល្អមានពណ៌ ខ្មៅ ឬ ប្រផេះ បន្ទាប់មកច្របាច់ស្រទាប់គ្រាប់ចេញ ហើយលាងទឹកអោយស្អាត។
- ❋ យកគ្រាប់ទៅប្រឡាក់ ជាមួយផេះចង្ក្រាន (គឺយកផេះចាស់៧-១០ថ្ងៃ) អោយសព្វគ្រាប់ល្ហុងរួចយកមកពង្រាយ លើក្រដាស់កាសែតស្តើងៗដើម្បីអោយគ្រាប់រហ័ស ស្ងួត។





- ❋ សំដិលក្នុងម្លប់ មិនអោយត្រូវពន្លឺថ្ងៃ និងឧស្សាហ៍ជ្រោយត្រឡប់វា២ ទៅ ៣ដង ក្នុង១ថ្ងៃដើម្បីកុំអោយគ្រាប់ដុះផ្សិត។
- ❋ ទុកពី៧ ទៅ១០ថ្ងៃ យើងអាចយកគ្រាប់មកបណ្តុះបានហើយ បើយើងទុកគ្រាប់យូរពេក វាមិនអាចដុះបានល្អទេ។

## ២- ការបណ្តុះគ្រាប់:

យើងយកគ្រាប់ដែលហាលស្ងួតមកត្រាំ ទឹកចំនួន២ យប់បន្ទាប់មកស្រង់គ្រាប់ចេញយកជី វើគ ចំនួន ១០០cc លាយទឹក ២០L មកត្រាំគ្រាប់ ល្ហុងរយះ ពេល ២ម៉ោងទៀត ទើបយើងស្រង់វា ចេញយកមកបណ្តុះក្នុងកន្ទោង ឬថង់តែម្តង។ ការត្រាំគ្រាប់ជាមួយ ជីវើគ ធ្វើឲ្យគ្រាប់ដុះបានល្អហើយជួយការពារ ជំងឺរោគល្ហុងបានផង។



## ៣- ការរៀបចំដីដាក់ក្នុងកន្ទោងបណ្តុះ ៖

- ❋ យើងត្រូវយកដីផុសល្អចំនួន ៤ធុងស្តិចត្រូលាយ ជាមួយអាចម៍គោស្ងួតផុសចំនួន ១ធុងស្តិចត្រូ និងលាយជាមួយផេះអង្កាម(យកផេះចាស់១ឆ្នាំ) ចំនួន១ធុងស្តិចត្រូដែរ រួចយកមកលាយច្របល់ចូលគ្នាអោយសព្វល្អ។



ដីផុសល្អ អាចម៍គោស្ងួត ផេះអង្កាម

- ❋ យកថង់ទំហំ ៤ x ៧cm មកកាត់គែមតូចទាំងសងខាងចេញហើយយកដីដែលលាយរួចមកច្រកចូល ក្នុងកន្ទោងថង់ជិតពេញ រួចដាក់គ្រាប់ពូជចំនួន ២គ្រាប់ចំកណ្តាលទន្ទឹមគ្នាហើយយក